# សម្ភាសន៍ជាមួយ នេន កន ភេទប្រុស អាយុ៦២ឆ្នាំ

## រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ ចាន ប្រុញ

## ០០:០៨:១២

## ៤ទំព័រ

ប្រុញៈ ខ្ញុំឈ្មោះប្រុញ ខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាដូចគ្នា ហើយខ្ញុំចង់សួរអ៊ំបន្តពាក់ព័ន្ធរឿងតុលាការបន្តិច ដែលរាល់ថ្ងៃគេកំពុងមានការជំនុំជម្រះមេដឹកនាំខ្មែរក្រហមធំៗមួយចំនួន អ៊ីចឹងចង់សួរអ៊ំ ។ អត់ទោសដំបូងអ៊ំឈ្មោះអី?

កនៈ នេន កន ។

ប្រុញៈ នេន កន?

កនៈ បាទ!

ប្រុញៈ អ៊ំអាយុប៉ុន្មាន?

កនៈ ៦២ ។

ប្រុញៈ អ៊ំមានស្រុកកំណើតនៅណា?

កនៈ នៅមណ្ឌលគិរី ។

ប្រុញៈ ស្រុកអីគេ?

កនៈ ស្រុករ៊ើនសែ ។

ប្រុញៈ ឃុំ?

កនៈ ឃុំប៉ពី ។

ប្រុញៈ ភូមិអីគេ?

កនៈ ភូមិក-២ ។

ប្រុញៈ អ៊ំបានដឹងពីរឿងការកាត់ទោសមេដឹកនាំសម័យខ្មែរក្រហមទេ?

កនៈ អត់ដឹង ។

ប្រុញៈ បច្ចុប្បន្ននេះគេមានការកាត់ទោសមេដឹកនាំធំៗ គេអត់កាត់ទោសអ្នកនៅតូចៗក្រោមទេ គេកាត់ទោសអ្នកធំៗ អ៊ីចឹងចង់សួរអ៊ំ តើការកាត់ទោសមេដឹកនាំធំៗហ្នឹងអ៊ំគិតថាម៉េចដែរ?

កនៈ អត់គិតថាម៉េច បើកាត់ទោសក៏កាត់ទោសទៅ គាត់ដឹកនាំខុសហើយធ្វើម៉េច ។


66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
t (855-23) 211-875 ◆ f (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

ប្រុញៈ អ៊ំយល់ថាបើគាត់ខុសកាត់ទោសអត់អីទេ?

កនៈ បាទ! បើខ្ញុំទ្រាំរបបហ្នឹងលែងបានហើយ អ្នកណាកាត់ទោសៗទៅ វាជាការងាររបស់គាត់ ព្រោះគាត់មេគ្រប់គ្រងខុសហើយខុស ប្រជាជនស្អប់ទូទាំងប្រទេស ដឹកនាំអីចឹងប្រជាជនដែរ ខ្ញុំក៏ស្អប់ដែរ ។

ប្រុញៈ អ៊ំម៉េចដឹងថាគាត់ដឹកនាំខុស?

កនៈ មិនខុសម៉េចបើ៣ឆ្នាំរំគេអស់ ចេះតែរំ ស៊ីបាយមិនឆ្អែតក៏រំគេដែរ បងប្អូនគ្នាឯងខុសក៏យកគ្នារំចោលដែរ មិនស្គាល់បងស្គាល់ប្អូនខុស គេកំពុងបង្រួបបង្រួមខ្មែរកុំឲ្យទៅប្រទេសក្រៅផង ។ ប្រទេសក្រៅបបួលតាំងពីជនភៀសខ្លួន ដូចអាមេរិកសុទ្ធតែជនភៀសខ្លួន មួយជួរអាមេរិកកាំងដាក់ជនជាតិអាមេរិកកាំង ប្រជាជនវាមានទៅណាប់អី ណាប់តែជនភៀសខ្លួន ជនជាតិអាមេរិកកាំងមានទៅរំណា យកជនជាតិគេទៅរំនោះ អត់មានយកប្រទេសអាមេរិកកាំងមករំណា យកជនជាតិក្រៅមករំ ដាក់ទង់ជាតិអាមេរិកកាំង ខ្មែរយើងគេចង់ធ្វើអីចឹង តែខ្មែរឡើងធ្វើធំ ទៅដឹកនាំខុស កាត់ទោសកាត់ទៅ ខ្ញុំអត់ទៅជំទាស់ជាមួយគេកាត់ទោស ខ្ញុំអត់ចង់បានទេរបបហ្នឹង ។

ប្រុញៈ ឧទាហរណ៍គេមានការចាត់តាំងមេធាវីមួយឲ្យការពារគាត់ តើអ៊ំគិតថាម៉េចដែរ? ប៉ុន្តែមេធាវីហ្នឹងគាត់ធ្លាប់ជាជនរងគ្រោះសម័យហ្នឹងដែរ តើអ៊ំគិតថាម៉េចដែរ? អាចមានយុត្តិធម៌ទេក្នុងការពារគាត់?

កនៈ ជនរងគ្រោះទៅកាត់ទោសធ្វើមេធាវីដែរ អីចឹងរួចខ្លួន ។ ឯងរងគ្រោះទៅកាត់ទោសគេទៀតទៅធ្វើមេធាវីទៀតរួចខ្លួនឯង ពីមុនឯងរួចខ្លួនដោយសារគេ ស្រាប់តែឥឡូវទៅធ្វើមេធាវី អ្នកធ្វើរួចខ្លួនបាត់ហើយ មិនមែនអ្នកជាណា ពីមុនគេធ្វើបាបឯង ដល់ពេលចុងបញ្ចប់ធ្វើមេធាវីរួចខ្លួនអស់ ។

ប្រុញៈ អីចឹងបានន័យថាបើគាត់ធ្លាប់ជាជនរងគ្រោះ ហើយគាត់ទៅការពារឲ្យជនដៃដល់ហ្នឹង គាត់ហ្នឹងអ៊ំគិតថាម៉េចឆ្កួត?

កនៈ ឆ្កួត ។

ប្រុញៈ ហេតុអី?

កនៈ មិនឆ្កួតម៉េច បើពីមុនគេរុកគួនឯង ដល់ពេលគេកាត់ទោសគាត់ហើយ មករកឯងវិញ ។

ប្រុញៈ អ៊ំនិយាយហ្នឹង មានន័យថាគាត់ធ្លាប់ជាជនរងគ្រោះ ហើយការពារឲ្យជនដៃដល់ អីចឹងអ៊ំគិតថាគាត់អាចលំអៀង?

កនៈ អត់លំអៀងទេ គ្រាន់តែថាអ្នកនៅរស់ឆ្កួតបាត់ហើយអត់ជាទេ ។

ប្រុញៈ ខ្ញុំអត់សូវយល់ អ៊ំចង់និយាយថា ធម្មតាអ្នកជនរងគ្រោះមិនអាចទៅការពារឲ្យជនដៃដល់ត្រូវទេអ៊ំ?

កនៈ អីចឹង អ្នកដៃដល់គេមកពីឯងវិញ មកពីមេធាវីហ្នឹងវិញ ពីមុនគេធ្វើបាបវា ដល់ឥឡូវមេធាវីហ្នឹងរួចខ្លួន ដល់ទីបញ្ចប់មកពីមេធាវី ។

ប្រុញៈ ជនដៃដល់ហ្នឹងអ្នកឈ្នះ ឬមេធាវីឈ្នះ?

កនៈ មេធាវីឈ្នះ ។

ប្រុញៈ អីចឹងមេធាវីហ្នឹងមិនអាចការពារជនដៃដល់បាន?

កនៈ ម៉េចបាន អាមួយនេះមកវ៉ៃបងឯង បងឯងរួចរាល់ហើយ ទៅពឹងអានោះដដែល ឯងរកវ៉ៃគេមុននោះគ្នាងាប់ ដុតពីងាប់ចុងបញ្ចប់មកពីគេដដែលគេខឹង ឯងរកគេបានអ្នកហ្នឹងឈ្នះដដែល ។

វណ្ណៈ : ចង់និយាយថាខ្លួនឯងជាជនរងគ្រោះហើយទៅជួយអ្នកដែលធ្វើបាបខ្លួនឯងទៀត ។

កនៈ អីចឹងវាទៅជាឈ្នះ ។

ប្រុញៈ ឧទាហរណ៍ថាគាត់ជាជនរងគ្រោះសម័យហ្នឹងហើយ គាត់ធ្វើជាមេធាវីរាល់ថ្ងៃនេះ ហើយតុលាការចាត់តាំងគាត់ឲ្យការពារជនដៃដល់ហ្នឹង តើសំរាប់ក្នុងផ្លូវច្បាប់ ឬក្នុងផ្លូវពិតប្រាកដ តើមេធាវីហ្នឹងគាត់អាចការពារជនដៃដល់ហ្នឹង មានប្រសិទ្ធិភាពទេ?

កនៈ អត់ទេ ដល់ពេលដុតរួចរាល់ នោះបានដុតហើយវាលំបាក ។

ប្រុញៈ ចង់និយាយថាគាត់ប្រឹងប្រែងការពារជនដៃដល់អត់?

កនៈ មិនដឹងម៉េច ខ្ញុំអត់យល់ដែររឿងហ្នឹង មិនដឹងថាម៉េច អាអ្នកវ៉ៃឈើមួយសារ ហើយឲ្យការពារទៀត មិនដឹងម៉េច ស្រេចតែគេមិនដឹងដែរ ។

ប្រុញៈ តែសំរាប់អ៊ំជាជនរងគ្រោះសម័យហ្នឹង ហើយឥឡូវគេចាត់តាំងអ៊ំឲ្យទៅការពារជនដែលធ្លាប់ធ្វើបាបអ៊ំ តើអ៊ំគិតម៉េចសំរាប់អ៊ំ?

កនៈ អត់ធ្វើទេ ឆ្អែតហើយ ធ្វើអីទៀតបើគេធ្វើបាបហើយ ។

ប្រុញៈ អ៊ំអត់ចង់ការពារម្នាក់ហ្នឹងតែម្តង ឬយ៉ាំងម៉េច?

កនៈ អត់ការពារទេ អ្នកច្បាប់អត់ការពារទេ អ្នកធ្វើបាប ខ្ញុំអត់ធ្វើទេ ទោះបីកាត់ទោសទៅណាទៅៗ យកទៅសម្លាប់ចោលក៏សម្លាប់ទៅ ខ្ញុំអត់រវីរវល់ ម៉ែឪខ្ញុំអស់២នាក់ ម៉ែឪខ្ញុំនៅក្មេងៗដែលខ្ញុំចេញទៅធ្វើទ័ព សម្លាប់អស់រលីង កាត់ទោសៗទៅ ការពារៗទៅ ខ្ញុំអត់ធ្វើទេ ។

ប្រុញៈ អ៊ំមានគ្រួសារស្លាប់សម័យហ្នឹងដែរ?

កនៈ មាន ។

ប្រុញៈ	សម័យពាឆ្នាំ?

កនៈ	ម៉ែឪ ។

ប្រុញៈ	ស្លាប់ក្នុងចន្លោះហ្នឹងដែរ?

កនៈ	នេះបងប្រពន្ធខ្ញុំអស់បងម្នាក់ដែរ រកមិនទាន់ឃើញ ។

ប្រុញៈ	អ៊ំក្រោយឆ្នាំ៧៩មានគេឲ្យរៃតទល់ជាមួយវៀតណាមទេ?

កនៈ	អត់ទេ ។

ប្រុញៈ	អីចឹងអ៊ំរត់ចូលព្រៃដើម្បីអីគេ?

កនៈ	ខ្ញុំអត់មានរត់ចូលព្រៃណា៎ ។

ប្រុញៈ	អត់ទេអ៊ំ?

កនៈ	បាទ! កាលអ៊ុនតាក់មកទេ បានខ្ញុំមកនេះ ។

ប្រុញៈ	អីចឹងអត់អីអ៊ំ អរគុណច្រើន គ្រាន់តែចង់សួរយោបល់អ៊ំ អរគុណច្រើន ។

**ចប់**